# ៧ - ទីស្តីការក្រសួង សង្គមកិច្ចការងារ និង អតីតយុទ្ធជន

## ប្រកាស

រាជធានីភ្នំពេញ ,ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

**ប្រកាស លេខ : ០០៩ គក.ពក**

**គណៈកម្មការរៀបចំទិវាកីឡាជនពិការកម្ពុជា**

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រឹត្យ របស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះរាជាណាចក្រ កម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញសេចក្តីសំរេចលេខ១៥ សសរ ចុះថ្ងៃទី ០២-០២-១៩៩៥ របស រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតគណៈកម្មការ រៀបចំទិវាកីឡាជន ពិការ
- បានឃើញប្រកាសលេខ ៧១ សកអ. ចុះថ្ងៃទី ១០-០២-១៩៩៥ របស់ ក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន ស្តីពីការតែងតាំងឯកឧត្តម **ហ៊ុន លីហួត** អនុរដ្ឋលេខាធិការក្រសួង សង្គមកិច្ចការងារ និង អតីត យុទ្ធជន ជាប្រធានគណៈកម្មការរៀបចំទិវាកីឡាជនពិការកម្ពុជា
- យោងប្រកាសលេខ ០០៥ គក.ពក ចុះថ្ងៃទី ០១-០២-១៩៩៦ ស្តីពីបង្កើត លេខាធិការដ្ឋាន និង អនុគណៈកម្មការប្រតិបត្តិ
- យោងប្រកាសលេខ ០០៦ គក.ពក ចុះថ្ងៃទី ០២ -០២ - ១៩៩៦ ស្តីពី ការបែងចែកភារកិច្ច ដល់សមាជិកតំណាងអន្តរក្រសួង នៃគណៈកម្មការ រៀបចំទិវាកីឡាជនពិការកម្ពុជា

- យោងតាមស្មារតីអង្គប្រជុំ គណៈកម្មការរៀបចំទិវាកីឡាជនពិការកម្ពុជា ថ្ងៃទី ០៧-០២-១៩៩៦

**សំរេច**

**ប្រការ ១** : រៀបចំអធិបតីកិត្តិយសរួមមាន ÷

១-ឯកឧត្តម ស៊ុយ សែម រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន

២-ឯកឧត្តម ហុង ថែម អនុរដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន

៣-ជំទាវ នួន សូគិ អនុរដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន

**ភារកិច្ច** :

ជួយផ្តល់យោបល់សំរេចសំរបសំរួលដល់ករណីទាំងឡាយ នៃគណៈកម្មការរៀបចំទិវាកីឡាជន ពិការកម្ពុជា ។

**ប្រការ ២** : រៀបចំសមាជិកកិត្តិយសរួមមាន ÷

១-លោក មីវ ចៀង ប្រធានមន្ទីរ ក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន

២-លោក ទូច សាម៉ុន អនុប្រធាននាយកដ្ឋានចូលនិវត្តន៍ សង្គ្រោះសង្គម ក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន

៣-លោក កែវ សឿន ប្រធាននាយកដ្ឋានស្តារលទ្ធភាពពលកម្ម ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន

៤-លោក ហ៊ុយ ហានសុង ប្រធាននាយកដ្ឋានពេទ្យការងារ ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន

៥-លោក ហាំង ស៊ីថា ប្រធាននាយកដ្ឋានអធិការកិច្ច ការងារ ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន

៦-លោក ថាច់ សែម ប្រធាននាយកដ្ឋានសន្តិសុខសង្គម ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន

៧-លោក ឃឹម សន ប្រធាននាយកដ្ឋានមុខរបរ ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន

៨-លោក វង្ស វណ្ណា ប្រធាននាយកដ្ឋានបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន

៩-លោក គង់ សារា ប្រធាននាយកដ្ឋានជនពិការ ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន

**ភារកិច្ច :**

ជួយផ្តល់យោបល់ និង ជួយផ្តល់សមាសភាពមន្ត្រីរាជការ ក្រោមឱវាទជួយដល់គណៈ កម្មការលេខាធិការដ្ឋាន អនុគណៈកម្មការប្រតិបត្តិ ដែលមានការខ្វះខាត ។

**ប្រការ ៣ :** រៀបចំសមាសភាព និង ភារកិច្ចទីប្រឹក្សា នៃគណៈកម្មការរៀបចំទិវាកីឡាជនពិការកម្ពុជា ÷

១- ឧត្តមសេនីយ៍ ទុំ សំបុរ ទីប្រឹក្សាសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី ១ ទីប្រឹក្សាសហអគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ជាទីប្រឹក្សានៃគណៈកម្មការរៀបចំទិវាកីឡា ជនពិការកម្ពុជាជួយផ្តល់យោបល់ដល់គណៈកម្មការ និង ធ្វើការទំនាក់ទំនងជាមួយនឹង អគ្គលេខាធិការគណៈបក្ស ហ៊្វុនស៊ិនប៉ិចអំពាវនាវអញ្ជើញចូលរួមធ្វើវិភាគទានសប្បុរសធម៌ នៃ សមាជិកសមាជិកាគណៈបក្ស ។

២- ឧត្តមសេនីយ៍ មល រឿប ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី ២ ទីប្រឹក្សាសហអគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ជាទីប្រឹក្សាគណៈកម្មការរៀបចំទិវាកីឡាជនពិការកម្ពុជាជួយផ្តល់យោបល់ដល់គណៈកម្មការ និង ធ្វើការទំនាក់ទំនងជាមួយនឹង អគ្គលេខា

ធិការគណៈបក្សប្រជាជនកម្ពុជាអំពាវនាវអញ្ជើញចូលរួមធ្វើវិភាគទានសប្បុរសធម៌នៃសមាជិក សមាជិកា នៃគណៈបក្ស ។

៣- ឯកឧត្តម ព្រាប តាន់ នាយការិយាល័យទី ៥ នៃអគ្គសេនាធិការ កងយោធពល ខេមរភូមិន្ទ ជាទីប្រឹក្សាគណៈកម្មការរៀបចំទិវាកីឡាជនពិការកម្ពុជា ជួយផ្តល់យោបល់ដល់គណៈកម្មការ និង ធ្វើការទំនាក់ទំនង ក្នុងអគ្គសេនាធិការកងយោធពល ខេមរភូមិន្ទ ភូមិភាគ តំបន់ប្រតិបត្តិការសឹក រង អំពាវនាវ អញ្ជើញចូលរួមធ្វើវិភាគទានសប្បុរសធម៌ នៃនាយទាហាន នាយទាហានរង និងពលទាហាន ក្នុងកងយោធពលខេមរភូមិន្ទ ។

៤- ឧត្តមសេនីយ៍ ម៉ៅ ប៊ុន ណារិន ប្រធាននាយកដ្ឋានបុគ្គលិក នៃក្រសួងមហាផ្ទៃ ជាទីប្រឹក្សាគណៈកម្មការរៀបចំទិវាកីឡាជនពិការកម្ពុជា ជួយផ្តល់យោបល់ដល់គណៈកម្មការ និងធ្វើការទំនាក់ទំនងក្នុងអគ្គនាយកដ្ឋាននគរបាលជាតិ គ្រប់ស្នងការទាំងអស់ អំពាវនាវ អញ្ជើញចូលរួម ធ្វើវិភាគទានសប្បុរសធម៌ នៃនគរបាលជាតិ ។

៥- ឯកឧត្តម អ៊ូ គឹមស៊ន អនុរដ្ឋលេខាធិការ នៃទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអោយ ទីស្តីការគណៈរដ្ឋមន្ត្រី ជាទីប្រឹក្សាជួយផ្តល់យោបល់ដល់គណៈកម្មការធ្វើការទំនាក់ទំនងទៅ នឹងក្រសួងស្ថាប័ននានាក្នុងរាជរដ្ឋាភិបាល អំពាវនាវអញ្ជើញចូលរួមធ្វើវិភាគទានសប្បុរសធម៌ នៃមន្ត្រីរាជការ ។

៦- ឯកឧត្តម ស្រី វណ្ណផ្លង់ ទីប្រឹក្សាសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១ ជាទីប្រឹក្សា ជួយផ្តល់យោបល់ដល់គណៈកម្មការធ្វើការអំពាវនាវអញ្ជើញចូលរួម ធ្វើវិភាគទានសប្បុរសធម៌ នៃក្រុមហ៊ុនសហគ្រាសទាំងអស់ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

៧- លោក ប៊ូរិទ្ធី លន់ ជាទីប្រឹក្សាជួយផ្តល់យោបល់ដល់គណៈកម្មការធ្វើការទំនាក់ទំនងទៅនឹងអង្គការក្រៅរដ្ឋាភិបាលនានានៅក្នុងព្រះរាជាណាចក្រកម្ពុជា ធ្វើវិភាគទានអញ្ជើញ ចូលរួមសប្បុរសធម៌ នៃអង្គការទាំងនោះ ។

៨- លោក ស៊ី សុផុន តំណាងអង្គការ NGO និងក្រុមហ៊ុន ជួយផ្តល់យោបល់ដល់ គណៈកម្មការធ្វើការទំនាក់ទំនងជាមួយអង្គការ NGO ក្រៅប្រទេស និងក្រុមហ៊ុន អញ្ជើញចូលរួមធ្វើវិភាគទានសប្បុរសធម៌ នៃអង្គការ និងក្រុមហ៊ុននានា ។

**ប្រការ ៤** : បំពេញបន្ថែមភារកិច្ចដល់ ÷

– លោក ឡាក់ សំអាត អនុប្រធាន នៃគណៈកម្មការធ្វើការរៀបចំស្តង់តាំងពិពណ៌លក់ដូរក្នុងពហុកីឡាដ្ឋានជាតិអូឡាំពិក ជាមួយអនុប្រធានគណៈកម្មការហិរញ្ញវត្ថុក្នុងរយៈ ពេល ០៣ ថ្ងៃ គឺថ្ងៃ ២២-២៣-២៤ ខែ មីនា ឆ្នាំ ១៩៩៦ នេះ ។ ធ្វើការអំពាវនាវដល់ពាណិជ្ជករទាំងអស់អោយចូលរួមមកលក់ដូរឬតាំងពិពណ៌ឃោសនាលើមុខទំនិញរបស់ខ្លួន ។

–លោក កូវ គង់ តំណាងសាលាក្រុងភ្នំពេញ

–លោក ជា សន ប្រធានអធិការដ្ឋានសង្គមកិច្ច និងអតីតយុទ្ធជន រាជធានីភ្នំពេញ

–លោក លឹម អ៊ែលឡាដូ អនុគណៈកម្មការខ្មីមសារ រៀបចំបដាពាក្យស្លោកចែកផ្លូវ ថ្វល់អោយក្រុមហ៊ុនធ្វើ ហើយចែកគ្នាចងតាមផ្លូវក្នុងពហុកីឡាដ្ឋានជាតិអូឡាំពិក ។ សុំសិស្ស និស្សិត ប្រជាពលរដ្ឋក្រុងភ្នំពេញ ចូលរួមក្នុងកម្មវិធី ។

**ប្រការ ៥** : រៀបចំលេខាធិការដ្ឋាន នៃគណៈកម្មការរៀបចំទិវាកីឡាជនពិការកម្ពុជា

**សមាសភាព** :

១-លោក គង់ ថាន់ អនុប្រធានមន្ទីរក្រសួងសង្គមកិច្ចការងារនិងអតីតយុទ្ធជន ប្រធាន

២–លោក គង់ សារ៉ា ប្រធាននាយកដ្ឋានពិការ អនុប្រធាន

៣–លោក កែវ គឹមចុន អនុប្រធាននាយកដ្ឋានស្តារលទ្ធភាពពលកម្ម សមាជិក

៤–លោក ទៀវ សុគន្ធ អនុប្រធានមន្ទីរ ក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន សមាជិក

៥–លោក នី ស៊ីថន ប្រធានការិយាល័យរដ្ឋបាល, ស.ក.អ សមាជិក

៦-លោក លក គឹមសាន អធិការរងនៃអធិការដ្ឋានសង្គមកិច្ចការងារនិង
អតីតយុទ្ធជន សមាជិក

៧-លោក ម៉ែន រុន ការិយាល័យអន្តរជាតិ ក្រសួងសង្គមកិច្ចការងារ
និង អតីតយុទ្ធជន សមាជិក

៨-លោក ហៀង វាសនា ការិយាល័យអន្តរជាតិ ក្រសួងសង្គមកិច្ចការងារ
និងអតីតយុទ្ធជន សមាជិក

៩-លោក គួន ដានី ការិយាល័យអធិការកិច្ច ក្រសួងសង្គមកិច្ចការងារ
និងអតីតយុទ្ធជន សមាជិក

១០-ណូ សំបុក តំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការ
អន្តរជាតិ សមាជិក

**ប្រការ ៦ :** រៀបចំអនុគណៈកម្មការប្រតិបត្តិទាំង ៦ នៃគណៈកម្មការរៀបចំទិវាកីឡាជនពិការកម្ពុជា ÷

**អនុគណៈកម្មការបច្ចេកទេស :**

**សមាសភាព :**

១-លោក មាស សារិន ប្រធាននាយកដ្ឋានពហុកីឡាដ្ឋានជាតិអូឡាំពិក
ប្រធាន

២-លោក សូ សាមុត តំណាងក្រសួងអប់រំយុវជន និង កីឡា
អនុប្រធាន

៣-លោក សាមីឌី ស៊ីវឡូនា តំណាងសហព័ន្ធកីឡាកម្ពុជា អនុប្រធាន

៤-លោក យ៉ែម ឧត្តម តំណាងពហុកីឡាដ្ឋានជាតិអូឡាំពិក សមាជិក

៥-លោក ព្រំ ប៊ុនយី តំណាងពហុកីឡាដ្ឋានជាតិអូឡាំពិក សមាជិក

៦-វរៈសេនីយ៍ ទិត្យ ម៉េងឡុង ប្រធានមជ្ឈមណ្ឌលបំប៉នសុខភាព យោធិនពិការ (គៀនស្វាយ) សមាជិក

៧-លោក ម៉ិល កាដូ តំណាងសហព័ន្ធកីឡាជនពិការកម្ពុជា សមាជិក

៨–លោក សុន សុងហាក តំណាងនាយកដ្ឋានប្រតិបត្តិអង្គការជនពិការកម្ពុជា សមាជិក

៩–លោក ហួន ហេន តំណាងអង្គការ អេ អេ អរ ស៊ី ស៊ី សមាជិក

១០–លោក សុង សុជាតិ តំណាងអង្គការ ស៊ីម៉ាក សមាជិក

១១–លោក ប៊ុត បូរី តំណាងអង្គការមារីណុល សមាជិក

១២–លោក សយ ស៊ើង តំណាងអង្គការ វី អាយ សមាជិក

១៣–លោក នៅ សំណាង តំណាងអង្គការ វី វី អេ អេហ្វ អាយ សមាជិក

១៤–លោក ពិត សុខ តំណាងអង្គការកម្ពុជា ត្រឹស្ត សមាជិក

១៤–អ្នកស្រី ជិល អុល តំណាងអង្គការ ឌី ភី អាយ សមាជិក

**ខ - អនុគណៈកម្មការហិរញ្ញវត្ថុ :**

**សមាសភាព :**

១–លោក ដួង ហុង អនុប្រធានមន្ទីរ ក្រសួងសង្គមកិច្ចការងារនិងអតីតយុទ្ធជន ប្រធាន

២–លោក ទួត ប៊ុនឡុង ប្រធានការិយាល័យក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន អនុប្រធាន

៣–លោក មាស សារឿន តំណាងអង្គការជនពិការកម្ពុជា សមាជិក

៤–លោក វិលី ស្រ៊ុន ប្រធានអង្គការ ធី អូ សមាជិក

**គ - អនុគណៈកម្មការពិធីការនិងទំនាក់ទំនងសាធារណៈ ៖**

**សមាសភាព :**

១–លោក ជា សុខុម តំណាងគណៈកម្មការបុណ្យជាតិ អន្តរជាតិ ប្រធាន

២–លោក សាន សំបូរី តំណាងក្រសួងពត៌មាន អនុប្រធាន

៣–លោក ស៊ឹម សារ៉ាក់ តំណាងក្រសួងវប្បធម៌ សមាជិក

៤-លោក ទិត្យ សារុនរ៉េត តំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សមាជិក

៥-លោក ពៀម វាលី តំណាងគណៈកម្មការបុណ្យជាតិ អន្តរជាតិ សមាជិក

៦-លោក ហែម ថុន តំណាងពហុកីឡាដ្ឋានជាតិអូឡាំពិក សមាជិក

៧-លោក កែន ស៊ីហួត តំណាងពហុកីឡាដ្ឋានជាតិអូឡាំពិក សមាជិក

៨-លោក គួរ គង់ តំណាងសាលាក្រុងភ្នំពេញ សមាជិក

៩-លោក ជា សុវណ្ណា តំណាងក្រសួងវប្បធម៌ សមាជិក

១០-លោក ទេស ហេង តំណាងគណៈកម្មការបុណ្យជាតិ និងអន្តរជាតិ សមាជិក

**ឃ - អនុគណៈកម្មការរក្សាសុវត្ថិភាព :**

**សមាសភាព :**

១-ឧត្តមសេនីយ៍ គង់ សាវ៉ាន់ តំណាងនគរបាលរាជធានីភ្នំពេញ ប្រធាន

២-ឧត្តមសេនីយ៍ នាម អៀង តំណាងកងរាជអាវុធហត្ថ រាជធានីភ្នំពេញ អនុប្រធាន

៣-ឧត្តមសេនីយ៍ ភុំ ប៊ុនថន តំណាងក្រសួងការពារជាតិ អនុប្រធាន

៤-ឧត្តមសេនីយ៍ រស់ សុវណ្ណ តំណាងក្រសួងមហាផ្ទៃ អនុប្រធាន

**ង - អនុគណៈកម្មការសង្គ្រោះបន្ទាន់ :**

**សមាសភាព :**

១-លោក ជា សំណាង តំណាងក្រសួងសុខាភិបាល ប្រធាន

២-លោក មូ សឺន តំណាងនាយកដ្ឋានពេទ្យការងារ ស.ក.អ អនុប្រធាន

៣-លោក ម៉ែន នរិទ្ធ តំណាងសុខាភិបាល អនុប្រធាន

**ច - អនុគណៈកម្មការខ្វីមសារ :**

**សមាសភាព :**

| | | |
|---|---|---|
| ១–លោក លឹម អ៊ែល្សារ៉ាជ្ជូ | អនុប្រធានមន្ទីរ ក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន | ប្រធាន |
| ២–លោក គន់ យ៉ាន | តំណាងវិទ្យុជាតិ | អនុប្រធាន |
| ៣–លោក អ៊ុំ បណ្ណសិទ្ធ | តំណាងទូរទស្សន៍ជាតិ | អនុប្រធាន |
| ៤–លោក មាស ឈាន | តំណាងនាយកដ្ឋានជនពិការ ស.ក.អ | សមាជិក |
| ៥–លោក ឡុង សុជាតិ | តំណាងនាយកដ្ឋានជនពិការ | សមាជិក |
| ៦–លោក ហុង ហ៊ាន | តំណាងនាយកដ្ឋានជនពិការ | សមាជិក |
| ៧–លោក គឹម ហុង | តំណាងក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន | សមាជិក |
| ៨–លោក យិប ថាវិទ្ធិ | តំណាងក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន | សមាជិក |
| ៩–លោក អ៊ឹង គៀនហេង | តំណាងក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន | សមាជិក |
| ១០–កញ្ញា ជុំ ស៊ីណាត | តំណាងក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន | សមាជិក |
| ១១–កញ្ញា ពិន មុន្នី | តំណាងក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន | សមាជិក |

**ប្រការ ៧** : លេខាធិការដ្ឋាន និង អនុគណៈកម្មការប្រតិបត្តិទាំង ៦ ត្រូវអនុវ[illegible]ានល្អ នូវតួនាទី និងភារកិច្ចដែលបានកំណត់ទុកក្នុងប្រកាសលេខ ០០៥ គ. ក ចុះថ្ងៃទី០១ កុម្ភៈ ១៩៩៦ របស់គណៈកម្មការរៀបចំទិវាកីឡាជនពិការកម្ពុជា ។

**ប្រការ ៨ :** កំណត់យកថ្ងៃសុក្រទី ២២ សៅរ៍ទី ២៣ អាទិត្យទី២៤ ខែ មីនា ឆ្នាំ ១៩៩៦ ជាទិវាកីឡាជនពិការកម្ពុជា ប្រចាំឆ្នាំ ១៩៩៦ ។

**ប្រការ ៩ :** អធិបតីកិត្តិយស សមាជិកកិត្តិយស ទីប្រឹក្សា លេខាធិការ អនុគណៈកម្មការប្រតិបត្តិ ចូលរួមក្នុងកម្មវិធីតាមសេចក្តីអញ្ជើញរបស់ប្រធានគណៈកម្មការរៀបចំ ទិវាកីឡាជនពិការកម្ពុជា ។

**ប្រការ ១០ :** ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជ - គណៈកម្មការរៀបចំទិវាកីឡាកម្ពុជា

ប្រធាន

ហត្ថលេខា និង ត្រា

**ហ៊ុន លីហួត**

* * *

## ៨ - ទីស្តីការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

### ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

**ប្រកាសលេខ ០១៣ បទ -ប្រក**

**ស្តីអំពីការប្រើប្រាស់ប្លង់អោយលេខទូរស័ព្ទជាតិ**

**រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃ ០១/១១/៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា។